

# ប្រតិទិននៃការលើកទឹកចិត្តវ៉ាក់សាំង COVID-19

## ប្រជាជនអាចទទួលបាន $100 ក្នុងការទទួលយកការចាក់វ៉ាក់សាំងពេញលេញ

*ប្រជាជនអាចទទួលបាននៅពេលពួកគេចាក់វ៉ាក់សាំងដូសទីមួយសម្រាប់ J& ឬដូសទីពីរសម្រាប់ Pfizer ឬ Moderna ។*

ទៅកាន់គ្លីនិកវ៉ាក់សាំង PDPH COVID-19 មួយក្នុងចំណោមគ្លីនិកដែលចូលរួមទាំងនេះ ហើយចុះឈ្មោះដើម្បីទទួលបានការលើកទឹកចិត្តរបស់អ្នកតាមអ៊ីមែលក្នុងរយៈពេល 1-2 ថ្ងៃ ឬតាមសំបុត្រក្នុងរយៈពេល 10 - 14 ថ្ងៃ ។

កម្មវិធីចាប់ផ្តើមនៅថ្ងៃទី 16 កុម្ភៈ ហើយបន្តសម្រាប់រយៈពេល 6 សប្តាហ៍ ។

| ទីតាំង | អាសយដ្ឋាន | កាលបរិច្ឆេទ | ម៉ោង |
|---|---|---|---|
| មជ្ឈមណ្ឌល Belfield Rec | 2109 W Chew Ave, 19138 | រៀងរាល់ថ្ងៃព្រហស្បតិ៍<br>ទី 24 កុម្ភៈ<br>ទី 3, ទី 10 , ទី 17 , ទី 24 , ទី 31 មីនា | ម៉ោង 10 ព្រឹក - 4 រសៀល |
| Boost CDC | 6010 Lansdowne Ave, 19151 | រៀងរាល់ថ្ងៃព្រហស្បតិ៍<br>ទី 3, ទី 10, ទី 17, ទី 24, ទី 31 មីនា | ម៉ោង 10 ព្រឹក - 4 រសៀល |
| មជ្ឈមណ្ឌលគ្រីស្ទាន Brand New Life | 6301 Germantown Ave, 19144 | រៀងរាល់ថ្ងៃសៅរ៍<br>ទី 26 កុម្ភៈ<br>ទី 19 មីនា | ម៉ោង 10 ព្រឹក - 4 រសៀល |
| មជ្ឈមណ្ឌល Christy Rec | 728 S 55th St, 19143 | រៀងរាល់ថ្ងៃអង្គារ<br>ទី 22 កុម្ភៈ<br>ទី 1, ទី 8, ទី 15, ទី 22, ទី 29 មីនា | ម៉ោង 1 រសៀល - 6 ល្ងាច |
| Community Academy | 1100 E Erie Ave, 19124 | រៀងរាល់ថ្ងៃសៅរ៍<br>ទី 5, ទី 26 មីនា | ម៉ោង 10 ព្រឹក - 4 រសៀល |
| សាល Grand Yesha | 2308 Snyder Ave, 19145 | ទី 15, ទី 21 មីនា | ម៉ោង 10 ព្រឹក - 4 រសៀល |
| Global Leadership Academy | 4601 W Girard Avenue, 19131 | ថ្ងៃសៅរ៍<br>ទី 19 កុម្ភៈ | ម៉ោង 10 ព្រឹក - 4 រសៀល |
| មជ្ឈមណ្ឌល MLK Older Adult | 2100 Cecil B Moore Ave, 19121 | រៀងរាល់ថ្ងៃសុក្រ<br>ទី 4, ទី 25 មីនា | ម៉ោង 10 ព្រឹក - 4 រសៀល |
| Salvation Army | 55th និង ផ្សារ 19139 | រៀងរាល់ថ្ងៃសុក្រ<br>ទី 18,ទី 25 កុម្ភៈ<br>ទី 11, ទី 18 មីនា | ម៉ោង 12 រសៀល - 6 ល្ងាច |
| មជ្ឈមណ្ឌល Simpson Rec | 1010 Arrott St, 19124 | ថ្ងៃច័ន្ទ<br>ទី 28 កុម្ភៈ | ម៉ោង12 រសៀល - 5:30 ល្ងាច |
| មជ្ឈមណ្ឌល Waterview Rec | 5826 McMahon Ave, 19144 | ទី 16,ទី23 កុម្ភៈ<br>ទី 2 ,ទី 9 ,ទី 30 មីនា | ម៉ោង 10 ព្រឹក - 4 រសៀល |

***ការលើកទឹកចិត្តមាននៅតែគ្លីនិកដែលចូលរួមប៉ុណ្ណោះ*    * គ្មានសាច់ប្រាក់ ឬកាតផ្សេងៗនៅតាមនឹងកន្លែងឡើយ***

- មិនតម្រូវឲ្យមានការធានារ៉ាប់រង និងលេខសម្គាល់ឡើយ ។
    - ព័ត៌មានផ្ទាល់ខ្លួនត្រូវបានអនុញ្ញាតឱ្យប្រើសម្រាប់គោលបំណងសុខភាពសាធារណៈតែប៉ុណ្ណោះ ។
- សំបុត្រ SEPTA ឥតគិតថ្លៃចំនួន 2 មាននៅនឹងកន្លែង ។
- មានការបកប្រែផ្ទាល់មាត់គ្រប់ភាសា ។

**វ៉ាក់សាំងដែលផ្តល់ជូនមាន Pfizer (អាយុ 5+), Moderna និង Johnson & Johnson (អាយុ 18+)**

Department of Public Health
CITY OF PHILADELPHIA



# កម្មវិធីលើកទឹកចិត្តវ៉ាក់សាំង COVID-19

## តើកម្មវិធីលើកទឹកចិត្តវ៉ាក់សាំង COVID-19 ជាអ្វី?

- ប្រជាជនដែលមានលក្ខខណ្ឌគ្រប់គ្រាន់អាចចុះឈ្មោះដើម្បីទទួលបាន $100 សម្រាប់ការចាក់វ៉ាក់សាំងពេញលេញ ។
  - *ប្រជាជនអាចទទួលបាននៅពេលពួកគេចាក់វ៉ាក់សាំងដូសទីមួយសម្រាប់ J&J ឬដូសទីពីរសម្រាប់ Pfizer ឬ Moderna ។*
  - ព័ត៌មានបន្ថែមមាននៅលើ៖ http://bit.ly/fullyvaccinatedincentive

**អ្នកនឹងមិនទទួលបាន $100 នៅថ្ងៃចាក់វ៉ាក់សាំងទេ ហើយគ្មានសាច់ប្រាក់ ឬកាតផ្សេងៗនៅនឹងកន្លែងដែរ ។**

| មានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការលើកទឹកចិត្ត | មិនមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការលើកទឹកចិត្ត |
|---|---|
| ទទួលយកវ៉ាក់សាំងដូសទីមួយរបស់អ្នកសម្រាប់ J&J<br><br>ទទួលយកវ៉ាក់សាំងដូសទីពីររបស់អ្នកសម្រាប់ Pfizer ឬ Moderna<br>*សូមនាំយកឯកសារពាក់ព័ន្ធនៃវ៉ាក់សាំងដូសទី 1 របស់អ្នក ឬប្រសិនបើអ្នកបានចាក់វ៉ាក់សាំងនៅ Philly យើងអាចរកមើលកំណត់ត្រាវ៉ាក់សាំងរបស់អ្នកបាន ។ | ទទួលយកវ៉ាក់សាំងដូសទីមួយរបស់អ្នកសម្រាប់ Pfizer ឬ Moderna<br>ទទួលយកវ៉ាក់សាំងដូសជម្រុញសម្រាប់ Pfizer, Moderna ឬ J&J<br>អ្នកមានអាយុក្រោម 18 ឆ្នាំ ហើយមិនមានវត្តមានឪពុកម្តាយ ឬអាណាព្យាបាល<br>អ្នកមិនមែនជាពលរដ្ឋនៅ Philadelphia<br>*សំបុត្រមួយសន្លឹកដែលមានឈ្មោះរបស់អ្នក និងអាសយដ្ឋាននៅ Philadelphia ក៏បាន ។<br>អ្នកជានិយោជិតនៅទីក្រុង |

**កុមារដែលមានអាយុចាប់ពី 11 ឆ្នាំឡើងទៅអាចយល់ព្រមឲ្យចាក់វ៉ាក់សាំងដោយខ្លួនឯងបាន ។ តើពួកគេអាចទទួលបានការលើកទឹកចិត្តទេ?**

- មែនហើយ កុមារដែលមានអាយុពី 5 - 17 ឆ្នាំអាចទទួលបានការលើកទឹកចិត្តនេះ ប៉ុន្តែឪពុកម្តាយ ឬអាណាព្យាបាលត្រូវតែមានវត្តមានដើម្បីយល់ព្រមចំពោះការលើកទឹកចិត្តនេះ ។

**តើខ្ញុំអាចទទួលបានការលើកទឹកចិត្តនៅកន្លែងណាក៏បានដែលវ៉ាក់សាំងត្រូវបានផ្តល់ជូននៅទីក្រុង Philadelphia បានទេ?**

- ជាអកុសល មូលនិធិមានកំណត់ ។ ការលើកទឹកចិត្តត្រូវបានផ្តល់ជូនតែនៅតាមទីតាំងនៅខាងក្រោយទំព័រនេះ និងនៅ http://bit.ly/fullyvaccinatedincentive

**ហេតុអ្វីបានជា PDPH ផ្តល់ប្រាក់សម្រាប់មនុស្សឲ្យចាក់វ៉ាក់សាំងឥឡូវនេះ ហើយហេតុអ្វីបានជាការលើកទឹកចិត្តមិនត្រូវបានផ្តល់ជូនសម្រាប់មនុស្សដែលទទួលបានដូសដំបូងសម្រាប់វ៉ាក់សាំងដែលត្រូវចាក់ 2 ដូស?**

- ប្រជាជននៅ Philadelphia ជាច្រើនបានទទួលដូសដំបូងរបស់ពួកគេរួចហើយ ។ សម្រាប់ហេតុផលជាច្រើន មិនមែនគ្រប់គ្នាសុទ្ធតែត្រូវបានចាក់វ៉ាក់សាំងពេញលេញនោះទេ ។
- នៅ Philadelphia មនុស្សដែលមិនបានចាក់វ៉ាក់សាំងពេញលេញ នៅតែមានហានិភ័យខ្ពស់ក្នុងការកើតជំងឺ COVID-19 កំពុងសម្រាកនៅមន្ទីរពេទ្យជាមួយជំងឺ COVID-19 ឬកំពុងចម្លងមេរោគទៅអ្នកដទៃ ។
- យើងចង់លើកទឹកចិត្តមនុស្សឲ្យបោះជំហានបន្ទាប់ និងទទួលបានវ៉ាក់សាំងពេញលេញ ។

**ហេតុអ្វីបានជាអ្នកកំពុងផ្តល់ជូនវ៉ាក់សាំង J&J នៅពេលដែលមានការព្រួយបារម្ភអំពីសុវត្ថិភាពមួយចំនួនអំពីវ៉ាក់សាំងនេះ?**

- J&J ផ្តល់ការការពារគ្រប់គ្រាន់ប្រឆាំងនឹង COVID-19 ។ វាកំពុងត្រូវបានផ្តល់ជូនសម្រាប់អ្នកដែលមិនមានបំណង ឬមិនអាចចាក់វ៉ាក់សាំងពីរដូស (Pfizer ឬ Moderna) ។

**ចុះមនុស្សទាំងអស់ដែលបានចាក់វ៉ាក់សាំងពេញលេញរួចហើយ តើពួកគេនឹងទទួលបាន 100$ដែរឬទេ?**

- នៅពេលមានជំងឺរាតត្បាតនេះ វិធីល្អបំផុតដើម្បីការពារអ្នកគ្រប់គ្នានៅក្នុងសហគមន៍របស់យើង ហើយខិតទៅជិតការបញ្ចប់នៃជំងឺរាតត្បាតនេះ គឺត្រូវឲ្យប្រជាជនកាន់តែច្រើនទទួលបានការចាក់វ៉ាក់សាំងពេញលេញ ។
  - នោះហើយជាមូលហេតុដែលការលើកទឹកចិត្តមានសម្រាប់តែអ្នកដែលទទួលបានដូសដំបូងសម្រាប់ J&J ឬពីរដូសសម្រាប់ Pfizer ឬ Moderna ប៉ុណ្ណោះ ។

Department of Public Health
CITY OF PHILADELPHIA